ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

សំណុំរឿងព្រហ្មទណ្ឌលេខ: ៦៦០
ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩
សំណុំរឿងស៊ើបសួរលេខ: ៣៨៧
ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩
សំណុំរឿងជំនុំជម្រះលេខ: ៣៥
ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០

**សាលក្រមព្រហ្មទណ្ឌ**
**លេខ ១០៩ "ក"**
ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពត

បានបើកសវនាការជាអសាធារណៈនៅសាលាដំបូងខេត្តកំពត។
កាលបរិច្ឆេទបើកសវនាការ៖ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ វេលាព្រឹក។
កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ វេលាព្រឹក។

**ដោយមានសមាសភាពដូចតទៅ**

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សានិងជាប្រធានសាលាដំបូងខេត្តកំពត
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦០ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ប៊ុនឡេង ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស កម្រិតវប្បធម៌ថ្នាក់ទី១០ ទីកន្លែងកំណើត និងទីលំនៅ បច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ប៊ុនលី "រស់" ម្តាយឈ្មោះ [redacted] ហេង "រស់" នៅលើវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៨៥ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ។

២.ឈ្មោះ [redacted] រិទ្ធី ហៅ រើ ភេទប្រុស អាយុ១៣ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតភូ[redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិស្នំប្រាំពីរ ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត ឪពុកឈ្មោះ [redacted] ហុន "រស់" ម្តាយឈ្មោះ [redacted] សុផាត "រស់" នៅលើវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

-ដីកាបង្គាប់ឱ្យដោះលែងលេខ ២២០ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ ។

៣.ឈ្មោះ [redacted] ហៃ ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស កម្រិតវប្បធម៌ថ្នាក់ទី៩ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន ស្ថិតនៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ទ្រី "រស់" ម្តាយឈ្មោះ [redacted] ណាក់ "រស់" នៅលើវ ជាអនីតិជន ទោសពីមិនគ្មាន ។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៨១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ។

៤.ឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស កម្រិតវប្បធម៌ថ្នាក់ទី៨ មានទីកន្លែងកំណើត និងទីលំនៅ បច្ចុប្បន្នស្ថិតនៅភ[redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ហេង "រស់" ម្តាយឈ្មោះ [redacted] មុំ "រស់" នៅលើវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៨៣ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ។



Scanned with CamScanner

៥. ឈ្មោះ [redacted] ចាន់វិចិត្រ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ស៊ីណាត "រស់" ម្តាយឈ្មោះ [redacted] សុខគួន "រស់" នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៩៥ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ។

៦. ឈ្មោះ [redacted] លីន ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ហ៊ុន "រស់" ម្តាយឈ្មោះ មុំ "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ១៩៩១ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

៧. ឈ្មោះ [redacted] វណ្ណដា ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ហុង "រស់" ម្តាយឈ្មោះ [redacted] មុំ "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ១៩៩២ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

<u>ជាប់ចោទពីបទ:</u> លួច (ជិះម៉ូតូឆក់ទូរស័ព្ទ) ប្រព្រឹត្តនៅចំណុចភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៨. ឈ្មោះ [redacted] ចេង ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងជួសជុលទូរស័ព្ទ កម្រិតវប្បធម៌ថ្នាក់ទី១០ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ជឹម "រស់" ម្តាយឈ្មោះ [redacted] មួយ "រស់" នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៩៩ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ។

<u>ជាប់ចោទពីបទ:</u> **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងកំពត ខេត្តកំពត នៅអំឡុងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

-មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡេង, [redacted] ចេង, [redacted] ឧត្តម , [redacted] ហៃ និងឈ្មោះ [redacted] ចាន់វិចិត្រ។

-ជនរងគ្រោះ [redacted] វីហ្សា ភេទស្រី អាយុ១៤ឆ្នាំ តំណាងដោយឈ្មោះ [redacted] រឹម ភេទប្រុស អាយុ៤០ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិតាអីប សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ នៅចំណុចភូមិសាស្ត្រក្រុងកំពត និងចុងក្រោយស្ថិតនៅមុខសាលារៀនចិន ជាងស៊ិន ស្ថិតនៅភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត មានករណី លួច (ជិះម៉ូតូឆក់ទូរស័ព្ទដៃ) និងទទួលផលចោរកម្ម បានកើតឡើង ដែលបង្កឡើងដោយជនសង្ស័យរួមមាន៖ ១.ឈ្មោះ [redacted] ប៊ុនឡេង ភេទប្រុស អាយុ ១៧ឆ្នាំ, ២.ឈ្មោះ [redacted] រិទ្ធី ហៅ រ៉េ ភេទប្រុស អាយុ១៥ឆ្នាំ, ៣.ឈ្មោះ [redacted] ហៃ ភេទប្រុស អាយុ១៦ឆ្នាំ, ៤.ឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ១៥ឆ្នាំ, ៥.ឈ្មោះ [redacted] ចាន់វិចិត្រ ភេទប្រុស អាយុ១៥ឆ្នាំ, ៦.ឈ្មោះ [redacted] លីន ភេទប្រុស អាយុ២០ឆ្នាំ, ៧.ឈ្មោះ [redacted] វណ្ណដា ភេទប្រុស អាយុ១៩ឆ្នាំ, ៨.ឈ្មោះ [redacted] ដារិទ្ធី ហៅ ង៉ែត ភេទប្រុស អាយុ១៥ឆ្នាំ និង ៩.ឈ្មោះ [redacted] ចេង ភេទប្រុស អាយុ២៨ឆ្នាំ បណ្តាលឱ្យឈ្មោះ [redacted] វីហ្សា ភេទស្រី អាយុ១៤ឆ្នាំ បានបាត់បង់ទូរស័ព្ទដៃមួយគ្រឿងម៉ាក វីវ៉ូ ពណ៌ខ្មៅ។ ក្រោយពេលកើតហេតុសមត្ថកិច្ចបានឃាត់ខ្លួន ១.ឈ្មោះ [redacted] ប៊ុនឡេង ភេទប្រុស អាយុ ១៧ឆ្នាំ, ២.ឈ្មោះ [redacted] ដារិទ្ធី ហៅ ង៉ែត ភេទប្រុស អាយុ១៥ឆ្នាំ, ៣.ឈ្មោះ [redacted] រិទ្ធី ហៅ រ៉េ ភេទប្រុស អាយុ១៥ឆ្នាំ, ៤.ឈ្មោះ [redacted] ចេង ភេទប្រុស អាយុ២៨ឆ្នាំ, ៥.ឈ្មោះ [redacted] ហៃ ភេទប្រុស អាយុ១៦ឆ្នាំ, ៦.ឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ១៥ឆ្នាំ និង៧.ឈ្មោះ [redacted] ចាន់វិចិត្រ ភេទប្រុស អាយុ១៥ឆ្នាំ នៅថ្ងៃទី១១ ខែកញ្ញា



Scanned with CamScanner

ឆ្នាំ២០១៩ ដោយឡែកឈ្មោះ [redacted] លីន ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] វណ្ណដា ភេទប្រុស អាយុ១៩ឆ្នាំ បានគេចខ្លួនបាត់។

## នាពេលសួរចម្លើយ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡេង ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ឆ្លើយថា៖ ខ្ញុំមិនបានប្រព្រឹត្តនោះទេ គឺឈ្មោះ [redacted] រិទ្ធី គ្រាន់តែខ្ញុំធ្លាប់ដើរលេងជាមួយវា មិនដឹងថាវាឆក់ទូរស័ព្ទទេ។ សមត្ថកិច្ចដកហូតម៉ូតូមួយគ្រឿងពីខ្ញុំ ម៉ាកសង់ប៊ិច ស៊េរីឆ្នាំ ២០១២ និងទូរស័ព្ទម៉ាកហ្វៃវ។ ខ្ញុំមិនបានចូលរួមលក់ទូរស័ព្ទ ឬយកលុយពីឈ្មោះ [redacted] រិទ្ធី នោះទេ។ ខ្ញុំស្គាល់ឈ្មោះ [redacted] រិទ្ធី និងឈ្មោះ [redacted] ហៃ និងឈ្មោះ [redacted] ចាន់វិចិត្រ ក្រៅពីនេះមិនស្គាល់ទេ។ ខ្ញុំដឹងឈ្មោះ [redacted] រិទ្ធី ជាអ្នកឆក់ព្រោះវាឆ្លើយនៅសមត្ថកិច្ច។ នៅថ្ងៃកើតហេតុខ្ញុំនៅផ្ទះ ដោយមានឪពុកម្តាយជាសាក្សី។ សមត្ថកិច្ចឃាត់ខ្លួនឈ្មោះ ហៃ, ឈ្មោះ ចិត្រ និងឈ្មោះ ឧត្តម។ ពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំ គឺខ្ញុំកំពុងជិះម៉ូតូរកទិញអីហូប។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហៃ ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ ឆ្លើយថា៖ ខ្ញុំស្គាល់ឈ្មោះ [redacted] ប៊ុនឡេង, ឈ្មោះ [redacted] ឧត្តម, ឈ្មោះ [redacted] ចាន់វិចិត្រ, ឈ្មោះ [redacted] ចេង, ឈ្មោះ [redacted] រិទ្ធី តែមិនស្គាល់ឈ្មោះ [redacted] លីន និងឈ្មោះ [redacted] វណ្ណដា នោះទេ។ ឈ្មោះ [redacted] ដារិទ្ធ បានយកទូរស័ព្ទមកឱ្យខ្ញុំធ្វើ ដោយវាប្រាប់ថាជាទូរស័ព្ទរបស់ប្អូនវា ហើយឈ្មោះ [redacted] ដារិទ្ធ បាននាំសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំ។ ហើយឈ្មោះ [redacted] ដារិទ្ធ ជាអ្នកលួចដោយសារវាឆ្លើយនៅសមត្ថកិច្ច។ ខ្ញុំយកទូរស័ព្ទទៅជួសជុលនឹងឈ្មោះ [redacted] ចេង មិនបានលក់ទេ។ ខ្ញុំមិនដឹងថាជាទូរស័ព្ទរបស់ឈ្មោះ [redacted] ដារិទ្ធ ដែលលួចគេនោះទេ ពេលនោះគឺឈ្មោះ [redacted] ដារិទ្ធ ប្រាប់ថាជាទូរស័ព្ទរបស់ប្អូនវាដែលជាប់សោរ វាបានឱ្យលុយខ្ញុំចំនួន ១០ដុល្លារអាមេរិក ហើយខ្ញុំក៏យកទូរស័ព្ទទៅឱ្យឈ្មោះ [redacted] ចេង ដែលជាគូរបស់ខ្ញុំជាអ្នកធ្វើអស់តែ៥ដុល្លាអាមេរិកទេ ហើយសមត្ថកិច្ចក៏មកឃាត់ខ្លួន។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ឆ្លើយថា៖ ខ្ញុំស្គាល់ឈ្មោះ [redacted] ប៊ុនឡេង, ឈ្មោះ [redacted] រិទ្ធី, ឈ្មោះ [redacted] ហៃ, ឈ្មោះ [redacted] ចាន់វិចិត្រ, ឈ្មោះ [redacted] លីន តែមិនស្គាល់ឈ្មោះ [redacted] វណ្ណដា និងឈ្មោះ [redacted] ចេង ទេ។ ខ្ញុំមិនដែលដើរលេង និងបានប្រាក់ពីអ្នកណាមកនោះទេ។ នៅសមត្ថកិច្ចគេវាយខ្ញុំ ហើយខ្ញុំក៏ឆ្លើយទៅ តែខ្ញុំមិនបានប្រព្រឹត្តនោះទេ។ ខ្ញុំគ្រាន់តែស្គាល់ដោយសាររៀននៅសាលាជាមួយគ្នាប៉ុណ្ណោះ។ នៅសមត្ថកិច្ចវាយខ្ញុំខ្លាំងពេក ទើបខ្ញុំទ្រាំមិនបានក៏ចេះតែឆ្លើយទៅ។ គ្នាខ្ញុំមានម៉ូតូមានឈ្មោះ ហៃ និងឈ្មោះ ឡុង។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់វិចិត្រ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ឆ្លើយថា៖ ខ្ញុំមិនស្គាល់ឈ្មោះ [redacted] លីន និងឈ្មោះ [redacted] វណ្ណដា ទេ តែស្គាល់ឈ្មោះ ឡេង, ឈ្មោះ ហៃ និងឈ្មោះ ឧត្តម និងឈ្មោះ ជួប ចេង។ ខ្ញុំក៏ស្គាល់ឈ្មោះ [redacted] រិទ្ធី និងឈ្មោះ [redacted] ដារិទ្ធ តែមិនដឹងថាវាឆក់ទូរស័ព្ទគេ ពេលកំពុងជិះជាមួយគ្នានៅម្តុំ BAMBOO Resort ពេលវាប្រាប់ហើយឈ្មោះ វីត បានលោតចុះពីលើម៉ូតូ។ សូមបញ្ជាក់ថាឈ្មោះ វីត បានមកជួបពួកខ្ញុំ ហើយប្រាប់ខ្ញុំថា មិត្តភក្តិវាទំលាក់វានៅនឹង ហើយពឹងខ្ញុំឱ្យជូនវាទៅផ្ទះ ពេលនោះខ្ញុំនិងឈ្មោះ [redacted] ហៃ ក៏បានដឹកវាទៅផ្ទះរបស់វា ឈ្មោះ វីត ប្រាប់ថាវាឆក់ទូរស័ព្ទគេ តែមិនមែនឆក់ពេលជិះម៉ូតូជាមួយខ្ញុំទេ គឺឆក់ជាមួយពួកម៉ាកវា។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចេង ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ឆ្លើយថា៖ ខ្ញុំមិនបានទិញទូរស័ព្ទពីពួកវាខាងលើនោះទេ គ្រាន់តែជាជាងជួសជុលទូរស័ព្ទ ពេលនោះពួកវាយកទូរស័ព្ទឱ្យខ្ញុំដោះលេខកូដតែប៉ុណ្ណោះ ហើយពេលនោះធ្វើដោះសោរអស់ ៥ដុល្លាអាមេរិក ហើយមិនធ្លាប់ជួសជុលច្រើនដងពីពួកវានោះទេ។ ខ្ញុំមិនបានបើកកន្លែងលក់ទូរស័ព្ទនោះទេ គ្រាន់តែជួសជុលប៉ុណ្ណោះ។ ខ្ញុំស្គាល់ឈ្មោះ [redacted] ហៃ ជាក្មួយប្រុសរបស់ខ្ញុំ ហើយឈ្មោះ ឧត្តម, ឈ្មោះ [redacted] និងឈ្មោះ ចិត្រ ខ្ញុំស្គាល់ព្រោះជាមិត្តភក្តិរបស់ក្មួយខ្ញុំឈ្មោះ [redacted] ហៃ។ ខ្ញុំជួសជុលដោយដោះលេខកូដ ហើយសួរវាដែរថាម៉េចបានជាជាប់លេខកូដ តែវាមិនប្រាប់។ល។

-តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានអំណានចម្លើយរបស់ឈ្មោះ [redacted] ដារិទ្ធិ, [redacted] រិទ្ធី, [redacted] ចេង, [redacted] ប៊ុនឡេង, [redacted] ឧត្តម, [redacted] ចាន់វិចិត្រ និងឈ្មោះ [redacted] ហៃ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។

-តុលាការបង្គាប់ឱ្យក្រឡាបញ្ជីបង្ហាញឯកសារជាសំបុត្រកំណើតរបស់ឈ្មោះ [redacted] ដារិទ្ធិ, [redacted] រិទ្ធី ។

-ការកត់សម្គាល់ខ្លីៗប្រហាក់ប្រហែលគ្នារបស់ជនជាប់ចោទទាំងប្រាំនាក់ថា៖សុំឱ្យតុលាការលើកលែងទោស និងបន្ធូរបន្ថយទោស។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ភស្តុតាងនានា និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ មានការស៊ីសង្វាក់គ្នាថាជនជាប់ចោទទាំងអស់ខាងលើ ពិតជាបាន លួច (ជិះម៉ូតូឆក់ទូរស័ព្ទដៃ) និងទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងកំពត និងចុងក្រោយស្ថិតនៅមុខសាលារៀនចិន ធានស៊ិន ស្ថិតនៅភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ហេតុនេះតំណា អយ្យការនៅតែតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចតាមផ្លូវច្បាប់។

-មេធាវីរបស់ជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីយើងខ្ញុំមិនបានចូលរួមប្រព្រឹត្តនោះទេ ដោយគ្រាន់តែម៉ូតូរបស់គាត់ត្រូវបានឈ្មោះ [redacted] ដារិទ្ធិ និងឈ្មោះ [redacted] រិទ្ធី បានយកម៉ូតូរបស់ពួកគាត់ទៅធ្វើសកម្មភាពតែប៉ុណ្ណោះ។ ហេតុនេះវិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់កូនក្តីខ្ញុំ ព្រោះចម្លើយនៅសមត្ថកិច្ចកូនក្តីយើងខ្ញុំបានបដិសេធចម្លើយនៅសមត្ថកិច្ចដោយសារតែគេវាយ។ ហើយមិនមានធាតុផ្សំគ្រប់គ្រាន់ក្នុងការប្រព្រឹត្តបទល្មើស និងស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់លើកូនក្តីយើងខ្ញុំ។ មួយវិញទៀតកូនក្តីយើងខ្ញុំជាអនីតិជន និងកំពុងសិក្សា ហើយគ្មានភស្តុតាងអ្វីក្រៅពីចម្លើយរបស់អ្នកដទៃឆ្លើយដាក់កូនក្តីខ្ញុំតែប៉ុណ្ណឹង។

-បានឃើញ សេចក្តីសន្និដ្ឋានការពារក្តី ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ការកត់សម្គាល់ខ្លីៗរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានា

-ក្រោយពីបានពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

## **សំអាងហេតុ**

១. តុលាការទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦០ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១២០១/១៩ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពត ធ្វើឡើង ក្នុងកំណត់ច្បាប់ ដូច្នេះ តុលាការអាចលើករឿងក្តីនេះមកជំនុំជម្រះតាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. ក្រោយពីបានសាកសួរដេញដោលនាពេលសវនាការ ទៅតាមអង្គហេតុនៅក្នុងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ របស់ចៅក្រមស៊ើបសួរ ដែលមានអង្គហេតុនៃអំពើ លួច (ជិះម៉ូតូឆក់ទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងកំពត និងចុងក្រោយស្ថិតនៅមុខសាលារៀនចិន ធានស៊ិន ស្ថិតនៅភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តដោយជនជាប់ចោទ១.ឈ្មោះ [redacted] ប៊ុនឡេង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិ ខ្មែរ, ២.ឈ្មោះ [redacted] រិទ្ធី ហៅ រ៉េ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ, ៣.ឈ្មោះ [redacted] ហៃ ភេទប្រុស អាយុ១៦ឆ្នាំ ជន ជាតិខ្មែរ, ៤.ឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ, ៥.ឈ្មោះ [redacted] ចាន់វិចិត្រ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ, ៦.ឈ្មោះ [redacted] លីន ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ, ៧.ឈ្មោះ [redacted] វណ្ណដា ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ, និងបទ ទទួល



Scanned with CamScanner

ផលចោរកម្ម ប្រព្រឹត្តនៅខែកញ្ញា ឆ្នាំ២០១៩ នៅចំណុចភូមិសាស្ត្រក្រុងកំពត ខេត្តកំពត តាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តដោយឈ្មោះ [redacted] ចេង ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ។

តុលាការយល់ឃើញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី, [redacted] ប៊ុន ឡេង, [redacted] ឧត្តម, [redacted] ចាន់វិចិត្រ និងឈ្មោះ [redacted] ហៃ ជាអំពើឆក់ហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃក្នុងគោលបំណងយកមក ធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ សកម្មភាពនៃការឆក់យកទូរស័ព្ទពីជនរងគ្រោះដែលកំពុងធ្វើដំណើរអាចបណ្តាលឱ្យជនរងគ្រោះ រងរបួសពិការ ឬអាចធ្ងន់ធ្ងរឈានដល់បាត់បង់ជីវិត។ ហេតុនេះការលួចរបស់ជនជាប់ចោទមានព្យសនកម្មធ្ងន់ធ្ងរ និងអំពើនេះជាការប្រព្រឹត្តដោយហិង្សា ដែលតុលាការគប្បីប្តូរបទចោទ មកជា បទ លួចមានស្ថានទម្ងន់ទោសដោយសារការ ប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣. ផ្អែកតាមសំបុត្រកំណើតលេខ ៧៩ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឃ្សឹម កំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី កើតថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៦ ហើយបទល្មើសប្រព្រឹត្តឡើងនៅអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ កំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី មានអាយុក្រោម១៤ឆ្នាំ គិតនៅពេលប្រព្រឹត្តបទល្មើស ដែលតុលាការត្រូវសម្រេចឱ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ស្របតាមមាត្រា ៤៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ដោយឡែក ចំពោះសំណង់រដ្ឋប្បវេណី តុលាការក៏មិនមានមូលដ្ឋានសម្រេចនោះដែរ ដោយសារមិនមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងនេះនោះទេ។

៤. ជនជាប់ចោទឈ្មោះ [redacted] ចេង ត្រូវបានបញ្ជូនមកជំនុំជម្រះ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងកំពត ខេត្តកំពត នៅអំឡុងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ប៉ុន្តែផ្អែកតាមការដេញដោលនាពេលសវនាការ ព្រមទាំងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហៃ ធៀបជាមួយនឹងចម្លើយរបស់ជនជាប់ចោទរូបនេះ មានភាពស៊ីចង្វាក់គ្នាថា ជនជាប់ចោទរូបនេះមិនមែនជាអ្នកលក់ទូរស័ព្ទដែលនោះទេ គ្រាន់តែជាជាងជួសជុលទូរស័ព្ទ ហើយខ្លួនក៏បានសួរអំពីប្រភពនៃទូរស័ព្ទដែលក្មួយខ្លួនឈ្មោះ [redacted] ហៃ យកមកធ្វើដែរ តែក្មួយប្រាប់ថាជារបស់មិត្តភក្តិរបស់គេ ទើបជនជាប់ចោទជួសជុលឱ្យ និងទទួលថ្លៃជួសជុលចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយគ្រឿង។ ហេតុនេះ កំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] ចេង តុលាការពិនិត្យមើលថាអំពើរបស់ជនជាប់ចោទមិនមែនជាបទល្មើសទេ ត្រូវបានរួចខ្លួនពីបទចោទ ស្របតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥. ជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡេង, ឈ្មោះ [redacted] ហៃ, ឈ្មោះ [redacted] ឧត្តម, ឈ្មោះ [redacted] ចាន់វិចិត្រ បានបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ហើយសុំបដិសេធចម្លើយរបស់ខ្លួនដែលឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ ដោយសារថាចម្លើយនោះជាការបង្ខំ។ តុលាការយល់ឃើញថា ជនជាប់ចោទទាំងបួននាក់បានបដិសេធនូវចម្លើយរបស់ខ្លួនដោយសារសមត្ថកិច្ចវាយនិងបង្ខំឱ្យឆ្លើយ ហើយពួកខ្លួនចេះតែឆ្លើយទៅ។ ចំណុចនេះមិនអាចឱ្យតុលាការមានជំនឿទុកចិត្តសោះឡើយ ដោយសារថាប្រសិនបើការបង្ខំឱ្យឆ្លើយក៏មិនមានអង្គហេតុដែលស៊ីចង្វាក់គ្នានឹងការប្រព្រឹត្តជាក់ស្តែង ព្រមទាំងមានជនរងគ្រោះ វត្ថុតាង ហើយទាំងដែលចម្លើយរបស់ខ្លួនបានឆ្លើយហើយ បែរជាមកបដិសេធដោយគ្មានភស្តុតាងដោះបន្ទុកទៅវិញ ហើយជនជាប់ចោទក៏អាចបដិសេធនូវចម្លើយរបស់ខ្លួននៅដំណាក់កាលណាមួយបើខ្លួនយល់ថាចម្លើយនោះមិនមានផលប្រយោជន៍សម្រាប់ខ្លួន ទាំងដែលខ្លួនបានផ្តិតម្រាមដៃលើចម្លើយរួចហើយក៏ដោយ។ ការផ្តិតម្រាមដៃលើឯកសារចម្លើយរបស់ជនជាប់ចោទគឺធ្វើឡើងដើម្បីកុំឱ្យជនជាប់ចោទបដិសេធ ឬផ្លាស់ប្តូរ ឬមិនទទួលស្គាល់នូវចម្លើយរបស់ខ្លួនដែលបានឆ្លើយរួចហើយ។ ហេតុនេះ ចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលសវនាការគ្រាន់តែជាចម្លើយឆ្លើយដោះសារយករួចខ្លួន ក្នុងគោលបំណងចង់គេចពីការទទួលខុសត្រូវនូវអំពើរបស់ខ្លួន និងគ្មានភស្តុតាងនោះទេ។

៦. ផ្អែកតាមសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទត្រង់ចំណុចសុំឱ្យកូនក្តីខ្លួនឈ្មោះ៖

[redacted] ប៊ុនឡេង, [redacted] ហៃ, [redacted] ឧត្តម និងឈ្មោះ [redacted] ចាន់វិចិត្រ រួចខ្លួនពីបទចោទ មិនអាចឱ្យតុលាការយកមកពិចារណានោះឡើយ ហើយចំណុចនេះមាននៅក្នុងចំណុចទី៥ នៃសំអាងហេតុខាងលើ។ ដោយឡែក ចំពោះចំណុចស្នើសុំឱ្យឈ្មោះ [redacted] ចេង រួចខ្លួនពីបទចោទ តុលាការបានសរសេរនៅក្នុងសំអាងហេតុទី៤ ខាងលើនេះហើយ។ ចំណែកឯ ការស្នើសុំឱ្យប្រគល់ម៉ូតូមួយគ្រឿង ដែលមានស្លាកលេខ ភ្នំពេញ ១BF - ១៤៣៩ ឱ្យឈ្មោះ [redacted] ប៊ុនលី។ ចំណុចនេះតុលាការ ពិនិត្យឃើញថា តាមចម្លើយរបស់ឈ្មោះ [redacted] ប៊ុនឡេង នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ៦៥៩ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ បានឆ្លើយថា *ជិះម៉ូតូមួយគ្រឿងម៉ាក សង់ប៊ិច ពណ៌ខៀវ ស៊េរីឆ្នាំ២០១២ ដក់កាបូបពីស្ត្រីជនបរទេស...* ។ កំណត់បានថា ម៉ូតូដែលឈ្មោះ [redacted] ប៊ុនលី ត្រូវជាឪពុករបស់ឈ្មោះ [redacted] ប៊ុនឡេង ស្នើសុំជាវត្ថុដែលសម្រាប់ប្រព្រឹត្តបទល្មើស ដែលត្រូវរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

៧. ជនជាប់ចោទឈ្មោះ [redacted] លីន និងឈ្មោះ [redacted] វណ្ណដា មិនព្រមចូលខ្លួនមកអះអាង និងបង្ហាញភស្តុតាង ឬសាក្សីដើម្បីយកមកជាអំណះអំណាងក្នុងការការពារខ្លួននៅដំណាក់កាលអយ្យការ និងនៅដំណាក់កាលចៅក្រមស៊ើបសួរ ហើយនៅពេលសវនាការក៏មិនបានចូលខ្លួនមកនោះដែរ បែរជារត់គេចខ្លួន ទាំងនេះវាស្តែងពីចេតនាគេចវេះ និងទទួលស្គាល់ចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។

៨. ជនជាប់ចោទឈ្មោះ [redacted] លីន និងឈ្មោះ [redacted] វណ្ណដា បានរត់គេចខ្លួន ហើយនៅដំណាក់កាលចៅក្រមស៊ើបសួរមិនបានដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទខាងលើនេះទេ។ ហេតុនេះ គប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចេញដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ និងស្របតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៩.មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡេង, ឈ្មោះ [redacted] ហៃ, ឈ្មោះ [redacted] ឧត្តម, ឈ្មោះ [redacted] ចាន់វិចិត្រ, ឈ្មោះ [redacted] លីន, ឈ្មោះ [redacted] វណ្ណដា ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចភូមិទ្វីខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

១០. ជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡេង, ឈ្មោះ [redacted] ហៃ, ឈ្មោះ [redacted] ឧត្តម, ឈ្មោះ [redacted] ចាន់វិចិត្រ, ឈ្មោះ [redacted] លីន, ឈ្មោះ [redacted] វណ្ណដា បានយល់ដឹងនូវអំពើរបស់ ខ្លួនថាជាអំពើលួចតែជនជាប់ចោទនៅតែបន្តប្រព្រឹត្ត ទោះបីដឹងថាជាអំពើខុសច្បាប់ទាំងនេះបានបង្ហាញឱ្យឃើញពីចេតនាទុច្ចរិតរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តបទល្មើស។

១១. ជនជាប់ចោទឈ្មោះ [redacted] លីន និងឈ្មោះ [redacted] វណ្ណដា គឺជានីតិជន ដែលមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួន នៅខណៈពេលដែលប្រព្រឹត្តបទល្មើស ដែលអាចបណ្តាលឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ព្រមទាំងទ្រព្យសម្បត្តិអ្នកដទៃ ដែលច្បាប់មានចែងឱ្យផ្តន្ទាទោសជាដាច់ខាត ។

១២. ជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡេង, ឈ្មោះ [redacted] ហៃ, ឈ្មោះ [redacted] ឧត្តម, ឈ្មោះ [redacted] ចាន់វិចិត្រ គឺជាអនីតិជន ដែលមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើផ្ទាល់ ខ្លួននៅខណៈពេលដែលប្រព្រឹត្តបទល្មើស ដែលអាចបណ្តាលឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ព្រមទាំងទ្រព្យសម្បត្តិ។ ជនត្រូវចោទទាំងបួននាក់ខាងលើជាអនីតិជន មូលទោសត្រូវបានបន្ថយដោយអតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ស្របតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១៣. ជនរងគ្រោះឈ្មោះ [redacted] រីហ្សា ភេទស្រី អាយុ១៤ឆ្នាំ តំណាងដោយឈ្មោះ [redacted] រីម ភេទប្រុស អាយុ ៤០ឆ្នាំ មិនបានមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ និងពេលសវនាការនោះទេ។ ដូច្នេះ តុលាការមិនមានមូលដ្ឋាន ក្នុងការសម្រេចអំពីផលប្រយោជន៍ក្នុងរឿងរដ្ឋប្បវេណីនោះទេ ដែលមានបញ្ញត្តិនៅក្នុងតាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។៚



Scanned with CamScanner

# ហេតុដូច្នេះសាលាដំបូងខេត្តកំពត

## សម្រេច

១ - កែប្រែបទចោទ ពីបទ លួច (ជិះម៉ូតូឆក់ទូរស័ព្ទ) ប្រព្រឹត្តនៅចំណុចភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ មកបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២ - ឱ្យរួចខ្លួនពីបទចោទលើជនជាប់ចោទ៖

ក. ឈ្មោះ [redacted] ចេង ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងជួសជុលទូរស័ព្ទ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្ថិតនៅ[redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted] ជឹម "រស់" ម្តាយឈ្មោះ[redacted] មួយ "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងកំពត ខេត្តកំពត នៅអំឡុងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

ខ. ឈ្មោះ [redacted] វិទ្ធី ហៅ រ៉េ ភេទប្រុស អាយុ១៣ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិស្នំប្រាំពីរ ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត ឪពុកឈ្មោះ [redacted] ហុន "រស់" ម្តាយឈ្មោះ [redacted] សុផាត "រស់" នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។

ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣ - ផ្តន្ទាទោសលើជនជាប់ចោទ៖

ក. ឈ្មោះ [redacted] ប៊ុនឡេង ភេទប្រុស អាយុ១៧ឆ្នាំ ជាអនីតិជន និងឈ្មោះ[redacted] ហៃ ភេទប្រុស អាយុ១៦ឆ្នាំ ជាអនីតិជន និងឈ្មោះ[redacted] ឧត្តម ភេទប្រុស អាយុ១៥ឆ្នាំ ជាអនីតិជន និងឈ្មោះ [redacted] ចាន់វិចិត្រ ភេទប្រុស អាយុ១៥ឆ្នាំ ជាអនីតិជន ដូចមានសាវតារជាតិខាងលើ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០២ (ពីរ) ឆ្នាំ តែទោសនេះអនុវត្តក្នុងពន្ធនាគារ កំណត់ ០១ (មួយ) ឆ្នាំ ទោសសល់ពីនេះព្យួរធម្មតា ។

ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ខ. ឈ្មោះ [redacted] លីន ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ជានីតិជន និងឈ្មោះ[redacted] វណ្ណដា ភេទប្រុស អាយុ១៩ឆ្នាំ ជានីតិជន ដូចមានសាវតារជាតិខាងលើ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ០៤ (បួន) ឆ្នាំ ។

ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិទី១ខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៩ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤ - បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] លីន ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ជានីតិជន និងឈ្មោះ [redacted] វណ្ណដា ភេទប្រុស អាយុ១៩ឆ្នាំ ជានីតិជន ដូចមានសាវតារជាតិខាងលើ ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ល



Scanned with CamScanner

៥ - វត្ថុដែលចាប់យក ដែលកំពុងតែរក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តកំពត តាមដីកាបង្គាប់ឱ្យគ្រប់គ្រង និងថែរក្សាវត្ថុតាងលេខ ១៩៨១ ព្រទ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ មាន៖ ម៉ូតូម៉ាក សង់ប៊ិច ស៊េរីឆ្នាំ ២០១២ ពណ៌ទឹកសមុទ្រ ពាក់ស្លាកលេខ ភ្នំពេញ 1BF - ១៤៣៩ ចំនួន មួយគ្រឿង រឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈចំពោះមុខជនជាប់ចោទនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាអសាធារណៈ ចំពោះមុខជនជាប់ចោទនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០។

- ទុកសិទ្ធិប្តឹងឧទ្ធរណ៍ និងប្តឹងទាស់តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |